រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៩

## ២-សេចក្តីសំរេច

### សេចក្តីសំរេចលេខ ២៤ សសរ
### ស្តីពីការផ្ទេរភារកិច្ច នៃរាជរដ្ឋាភិបាល

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

### សំរេច

ប្រការ១ : ផ្ទេរសិទ្ធិជូនឯកឧត្តម តុល ឡោះ ឧបនាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាល ជំនួសសម្តេចនាយករដ្ឋមន្ត្រីដែលត្រូវអញ្ជើញទៅសំរាក និងពិនិត្យសុខភាពនៅបរទេស ចាប់ពីថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៩៩ រហូតដល់សម្តេចនាយករដ្ឋមន្ត្រីអញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង និង ឯកឧត្តម តុល ឡោះ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

រាជធានីភ្នំពេញ ,ថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៩

### សេចក្តីសំរេចលេខ ២៥ សសរ
### ស្តីពីការកែសំរួល មនបញ្ញត្តិប្រូវតាត
### កម្ពុជា ឆ្នាំ ១៩៩១

***

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា